# បដិមាព្រះវិស្ណុព្រះហស្តប្រាំបីរកឃើញនៅភ្នំដា

*សិល្បៈសម័យដំបូងរបស់ខ្មែរ គឺផ្ដើមចេញពីតំបន់ខាងត្បូងដែលមានតំបន់ពីរសំខាន់ៗ គឺ អូរកែវ (សព្វថ្ងៃវៀតណាមខាងត្បូង) និងតំបន់ភ្នំដា (ស្រុកអង្គរបុរី ខេត្តតាកែវ)។ អ្វីដែលគេចាប់អារម្មណ៍ខ្លាំងអំពីសិល្បៈនៅតំបន់ភ្នំដានោះ គឺសិល្បៈលុងភ្នំ និងបដិមាករមួយចំនួន។ បដិមាដែលលេចឡើងដំបូង គឺច្រើនទាក់ទងនឹងនិកាយវៃស្នវ (និកាយគោរពដល់ព្រះវិស្ណុ) ឧទាហរណ៍ បដិមាព្រះវិស្ណុព្រះហស្តប្រាំបី ព្រះក្រឹស្ណ ព្រះរាម ព្រះពលរាម ព្រះបរសុរាម។ ការនិយមគោរពព្រះវិស្ណុនៅដំណាក់ដំបូងនេះ មិនមែនមានតែនៅស្រុកខ្មែរនាសម័យនោះប៉ុណ្ណោះទេ ពោល គឺតំបន់ផ្សេងទៀតនៅទឹកដីអាស៊ីអាគ្នេយ៍ក៏មានដូចគ្នាដែរ ជាក់ស្ដែង បដិមាព្រះវិស្ណុស.វ.ទី៥ រកឃើញនៅស្រីទេពប្រទេសថៃឡង់ដ៍ ជាដើម។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញអំពីបដិមាព្រះវិស្ណុមានព្រះហស្តប្រាំបីដ៏ល្បីល្បាញមួយដែលរកឃើញនៅតំបន់ភ្នំដា ស្រុកអង្គរបុរី ខេត្តតាកែវ។ តើបដិមានេះ មានប្រវត្តិ និងលក្ខណៈបែបណាខ្លះ?*

*បដិមាព្រះវិស្ណុព្រះហស្តប្រាំបីនេះ រកឃើញតាមរយៈការធ្វើកំណាយនៅភ្នំដា ស្រុកអង្គរបុរី ខេត្តតាកែវ ក្នុងឆ្នាំ១៩៣៥ ដោយអ្នកស្រាវជ្រាវ និងអ្នកអភិរក្សបេតិកភណ្ឌជនជាតិបារាំងម្នាក់ ឈ្មោះ ហង់រី ម៉ូហ្សេ* (Henri Mauger)*។ នៅពេលរកឃើញដំបូង បដិមានេះបានបាក់បែកផ្នែកមួយចំនួន ជាពិសេសផ្នែកខាងក្រោមត្រង់ជើងខាងស្ដាំ និងផ្នែកខាងលើត្រង់ដៃខាងឆ្វេង។ បដិមានេះធ្វើអំពីថ្មភក់ (ថ្មថ្មើមអណ្ដើក) មានកម្ពស់រហូតដល់ ២,៨៧ម៉ែត្រ ដែលអាចចាត់ទុកថាជាបដិមាព្រះវិស្ណុធ្វើអំពីថ្មភក់ដែលធំជាងគេ និងមានកម្ពស់ខ្ពស់ជាងគេបង្អស់នៅក្នុងសិល្បៈខ្មែរ។ ម្យ៉ាងវិញទៀត បដិមាព្រះវិស្ណុនេះទៀតសោត គឺជាបដិមាព្រះវិស្ណុមានព្រះហស្តប្រាំបីដំបូងគេនៅក្នុងសិល្បៈខ្មែរ។ បដិមានេះក៏មិនខុសពីបដិមាផ្សេងទៀតនៅសម័យដំបូងៗដែរ ពោល គឺសិល្បករស្ថាបនាឡើងដោយមានក្បាច់រាងដូចដែកក្រចកសេះជុំវិញដើម្បីធ្វើជាជន្ទល់សម្រាប់ទប់។ សព្វថ្ងៃ បដិមានេះកំពុងដាក់តាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា នាទីក្រុងភ្នំពេញ។*

*បដិមានេះពាក់មកុដរាងស៊ីឡាំងខ្ពស់ មានទម្រង់ព្រះភក្ត្ររាងមូលទ្រវែងក្នុងទម្រង់សមាធិ (ស្ងប់ស្ងាត់) ច្រមុះមានខ្នង់ ស្លឹកត្រចៀកវែង ព្រះនេត្របិទ (មានត្របក)។ ដងខ្លួនបដិមាមានភាពស៊ីគ្នាជាមួយនឹងស្មារបស់បដិមា។ បដិមានេះស្លៀកសំពត់ខ្លី មានក្ដីចេញពីប្រកពតែមួយ ដែលអាចចាត់ទុកជាសំពត់ចងក្បិនដំបូងៗដែលយើងអាចមើលឃើញនៅលើបដិមា។ ព្រះហស្តខាងស្ដាំកាន់កែតនកណ្ឌគ្រប់ទាំងអស់ ដែលព្រះហស្តខាងលើកាន់ភ្លើង ព្រះហស្តខាងក្រោមទី២កាន់*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

*ដំបងតូចមួយ ព្រះហស្តថ្នាក់ទី៣កាន់ស្បែកសត្វ និងព្រះហស្តក្រោមបង្អស់កាន់ដំបងធំរាងកោង។ ចំណែកព្រះហស្តឆ្វេងវិញ បានបាក់បែកនៅសល់តែខាងក្រោមពីរប៉ុណ្ណោះ ដែលព្រះហស្តមួយកាន់វជ្រ (គ្រាប់រន្ទះ) និងព្រះហស្តខាងក្រោមបង្អស់កាន់ថូទឹក។ ជាទូទៅ កេតនភណ្ឌទាំងនេះ គេមិនធ្លាប់ឃើញព្រះវិស្ណុកាន់នោះទេ ហើយភាគច្រើនព្រះវិស្ណុមានព្រះហស្ត៤ដែលរកឃើញនៅក្នុងសិល្បៈខ្មែរច្រើនតែកាន់កេតនភណ្ឌចំនួន៤ដូចគ្នា គឺកងចក្រ ដុំមូល (ផែនដី) ដំបង និងខ្យងស័ង្ខ។ ដូច្នោះហើយ ព្រះហស្តចំនួនពីរដែលបាត់បង់នោះ គេមិនដឹងថាកាន់កងចក្រ ខ្យងស័ង្ខ ឬដុំមូល (ផែនដី) ឬអត់ទេ។ លោក ព្យែរ ឌុយប៉ុង (Pierre Dupont) ដែលជាអ្នកស្រាវជ្រាវជនជាតិបារាំងធ្លាប់បានសិក្សាលម្អិតអំពីបដិមាខ្មែរនៅសម័យដំបូងៗនោះ បានសាកល្បងហៅបដិមាព្រះវិស្ណុនេះថា "**ហរិកម្ពុជេន្ទ្រ**" ដែលអាចប្រែថា "**ព្រះវិស្ណុនៃកម្ពុជា**" ឬ "**ម្ចាស់នៃកម្ពុជា**"។ ការហៅដូច្នេះគឺលោកយោងទៅតាមសិលាចារឹកមួយដែលរកឃើញនៅប្រាសាទភ្នំដា ចុះបញ្ជីលេខ K.549។ ក្រៅពីនេះ លោក ហ្សង់ បូហ្ស៊ីលីយែរ (Jean Bossilier) បានចាត់បដិមានេះចូលទៅក្នុងរចនាបថភ្នំដា ដែលមានអាយុកាលនៅចុងសម័យហ្វូណនដល់ដើមសម័យចេនឡា ក្នុងរវាងឆ្នាំ៥៤០ ដល់ ៦០០។ ប៉ុន្តែការសិក្សាថ្មីៗនេះដោយលោក* Nancy H. Dowling *បានសន្និដ្ឋានថា បដិមាដែលរកឃើញនៅភ្នំដារួមទាំងបដិមាព្រះវិស្ណុព្រះហស្តប្រាំបីនេះផង អាចសាងឡើងនៅរវាងដើមស.វ.ទី៧ ច្រើនជាង។ បន្ថែមពីនេះទៅទៀត ការសិក្សាលម្អិតរបស់លោក* Paul Lavy *អំពីបដិមាព្រះវិស្ណុ និងហរិហរនៅកម្ពុជាក្នុងសម័យមុនអង្គរ បានសាកល្បងពន្យល់អំពីមូលហេតុដែលព្រះរាជាជំនាន់នោះពេញនិយមគោរពព្រះវិស្ណុ (និកាយវៃស្នវ) ដោយលោកសន្និដ្ឋានថា ព្រះរាជាគឺដូចជាទេព គ្រាន់តែព្រះរាជាជាទេពនៅផែនដី និងព្រះវិស្ណុជាទេពនៅស្ថានសួគ៌ ហើយមានតួនាទីជាអ្នកគ្រប់គ្រង ថែរក្សាលោកដូចគ្នាដែរ។*

*ជារួមមក បដិមាព្រះវិស្ណុព្រះហស្តប្រាំបីដែលរកឃើញនៅភ្នំដា ស្រុកអង្គរបុរី ខេត្តតាកែវ បានបង្ហាញនូវភាពលេចធ្លោយ៉ាងខ្លាំងនៃសិល្បៈខ្មែរសម័យដំបូង។ លក្ខណៈទូទៅរបស់បដិមាច្រើនមានលំនាំតាមឥណ្ឌាក៏ពិតមែន ប៉ុន្តែសិល្បករខ្មែរបានព្យាយាមកែប្រែមកជារូបភាពសិល្បៈក្នុងតំបន់។ បដិមានេះ ប្រហែលជាមានព្រះនាមថា "ហរិកម្ពុជេន្ទ្រ" ដូចដែលសិលាចារឹកបាននិយាយអាចថាបាន បើទោះបីគេមិនមានភស្តុតាងច្បាស់យ៉ាងណាក៏ដោយ។*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*

## ឯកសារពិគ្រោះ


Boisselier, J. 1966. *Asie du Sud-Est, Le Cambodge*, Tome I, Paris.

Dalsheimer, N. & Dagens, B. 2001, *Les collections du musée national de Phnom Penh, L'art du Cambodge ancient,* EFEO, Paris.

Dowling, N. 1999. 'A new date for the Phnom Da images and its implications for early Cambodia'. *Asian Perspectives* 38 (1): 51-61.

Dupont, P. 1955. *La statuaire préangkorienne*, Paris.

Lavy, P. 2003. As in heaven, so on earth: the politics of Visnu, Siva and Harihara images in pre-Angkorian Khmer civilization. *Journal of Southeast Asian Studies* 34: 21-39.

Mauger, H. 1936. L'Àsram Mahà Rosei. in: *BEFEO*. Tome 36, pp. 65-95.

Manguin, P.Y. 2004. "The Archaeology of the Early Maritime polities of Southeast Asia," in Bellwood, P., and Glover, I. C. (eds.) *Southeast Asia: from Prehistory to History*, pp. 282–313. London: RoutledgeCurzon.

Vickery, M. 1998. *Society, Economics and Politics in Pre-Angkorian Cambodia: The 7th-8th Centuries*. Tokyo: The Toyo Bunko, The Centre for East Asian Cultural Studies for UNESCO.




រូបលេខ១៖ បដិមាព្រះវិស្ណុព្រះហស្តប្រាំបីរកឃើញនៅភ្នំដា រូបថតឆ្នាំ១៩៣៥ (ប្រភព៖ ហង់រី ម៉ូហ្សេ)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៖ បដិមាព្រះវិស្ណុព្រះហស្តប្រាំបីដាក់តាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

# អត្ថបទ៖ បដិមាព្រះវិស្ណុព្រះហស្តប្រាំបីរកឃើញនៅកម្ពុជា



រូបលេខ២៣៖ លម្អិតកេតភណ្ឌនៅព្រះហស្តខាងស្តាំ ផ្នែកខាងលើ (ភ្លើង និងដំបងតូច)



រូបលេខ២៤៖ លម្អិតកេតភណ្ឌនៅព្រះហស្តខាងស្តាំ ផ្នែកខាងក្រោម (ស្បែកសត្វ និងដំបងធំ)



រូបលេខ២៥៖ លម្អិតកេតភណ្ឌនៅព្រះហស្តខាងឆ្វេង (វជ្រ ឬគ្រាប់រន្ទះ)



រូបលេខ២៦៖ លម្អិតកេតភណ្ឌនៅព្រះហស្តខាងឆ្វេង (ថូទឹក)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី